United Nations
Educational, Scientific and
Cultural Organization

World Press
Freedom Day

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

សហការជាមួយ

Konrad Adenauer Stiftung · ក្លឹបអ្នកកាសែតកម្ពុជា Club of Cambodian Journalists · Cambodia Communication Institute · DMC Department of Media and Communication

# សេចក្តីប្រកាសព័ត៌មានបន្ទាន់

## ការប្រារពទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០១៣

***សុវត្ថិភាពក្នុងការនិយាយ ៖ ការធានាសេរីភាពក្នុងការបញ្ចេញមតិ នៅគ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់***

**៣ ឧសភា ២០១៣ ៨.០០-១២.០០**

**សណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ**

ទិវាសេរីភាពសារព័ត៌មានឆ្នាំ២០១៣នឹងអបអរការគំរប់ខួប២០ឆ្នាំរបស់ខ្លួន។ ថ្ងៃទី៣ខែឧសភា ត្រូវបានប្រកាសជាសាធារណៈជាទិវាសេរីភាពសារព័ត៌មានដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣និងឆ្លងតាមការអនុម័តរបស់សន្និសីទទូទៅរបស់អង្គការយូណេស្កូ លើកទី២៦ ឆ្នាំ១៩៩១។ វាជាថ្ងៃមួយសំរាប់លើកទឹកចិត្ត និងលើកកម្ពស់ដល់ការបង្កើតថ្មីដើម្បីគាំទ្រសេរីភាពសារព័ត៌មាន ជាថ្ងៃវាយតំលៃពីស្ថានភាពនៃសេរីភាពសារព័ត៌មានទូទាំងសកលលោក និងក៏ជាថ្ងៃរំលឹកដល់រដ្ឋាភិបាលដើម្បីឲ្យមានការតាំងចិត្តគោរពដល់សេរីភាពក្នុងការបញ្ចេញមតិ។

ប្រធានបទនៃទិវាសេរីភាពសារព័ត៌មានឆ្នាំ២០១៣ផ្តោតលើ **សុវត្ថិភាពក្នុងការនិយាយ: ការធានាសេរីភាពក្នុងការបញ្ចេញមតិនៅគ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់**។ ការប្រារព្ធពិធីអបអរទិវាសេរីភាពសារព័ត៌មានឆ្នាំនេះមានគោលបំណងផ្តល់ជាវេទិកាសន្ទនាមួយដល់អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយនិងអង្គការ សង្គមស៊ីវិលដើម្បីជជែកវែកញែកអំពីការប្រឈម និងបញ្ហានានាជុំវិញសុវត្ថិភាពរបស់អ្នកសារព័ត៌មាននៅកម្ពុជា។

វគ្គទីមួយនៃពិធីនេះនឹងនាំមកនូវទស្សនវិស័យរបស់អ្នកសារព័ត៌មានអាជីព ទាំងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព និងប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍នៅកម្ពុជា។ តើអ្វីខ្លះដែលនាយក កម្មវិធីនិពន្ធនាយក អ្នកកាសែត និងមន្ត្រីសិទ្ធមនុស្សនៅកម្ពុជាកំពុងតែប្រឈមក្នុងការធានាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន? តើរដ្ឋាភិបាល អង្គការអន្តរជាតិ សង្គមស៊ីវិល បណ្តាញសារព័តមាន និងវិស័យឯកជននានា មានតួរនាទីអ្វីខ្លះក្នុងការធានានូវសុវត្ថិភាពរបស់អ្នកសារព័ត៌មាន? វគ្គទី២ មានបំណងស្វែងរកដំណោះស្រាយ និងជំរុញឲ្យមាននូវគម្រោងទ្រទ្រង់ផ្លូវច្បាប់ និងបទប្បញ្ញត្តិនៅកម្ពុជា: តើច្បាប់និងបទប្បញ្ញត្តិដែលមានសព្វថ្ងៃមានប្រសិទ្ធភាពនិងគ្រប់គ្រាន់ឬទេសំរាប់ធានានូវសុវត្ថិភាពដល់អ្នកសារព័ត៌មានទាំងនោះ?

ទិវាសេរីភាពសារព័ត៌មានឆ្នាំ២០១៣នឹងប្រារព្ធធ្វើឡើងដោយការិយាល័យយូណេស្កូភ្នំពេញ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស រួមសហការជាមួយមូលនិធិ Konrad Adenaur Stiftung ប្រចាំប្រទេសកម្ពុជា វិទ្យាស្ថានសារគមនាគមន៍កម្ពុជា ក្លឹបអ្នកកាសែតកម្ពុជា និងដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**សំរាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់:**
កញ្ញា Jamie Lee (UNESCO) តាមរយះលេខទូរស័ព្ទ 078 77 21 44 ឬ hj.lee@unesco.org
កញ្ញា Zoe Latumbo (OHCHR)តាមរយះលេខទូរស័ព្ទ 012 79 01 78 ឬ zlatumbo@ohchr.org

United Nations Educational, Scientific and Cultural Organization

World Press Freedom Day

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

In Cooperation With

Konrad Adenauer Stiftung

Club of Cambodian Journalists

Cambodia Communication Institute

DMC Department of Media and Communication

**<u>FOR IMMEDIATE RELEASE</u>**

**Celebration of the World Press Freedom Day**

**Safe to Speak: Securing Freedom of Expression in All Media**

**3rd May 2013**

**Himawari Hotel**

**8:00 am-12:00 pm**

World Press Freedom Day 2013 marks and celebrates its 20th anniversary. 3 May was proclaimed World Press Freedom Day at the UN General Assembly in 1993 following a recommendation adopted at the 26th session of UNESCO's General Conference in 1991. It is a day to encourage and develop initiatives in favor of press freedom, to assess the state of press freedom worldwide, and to remind governments of the need to respect their commitment to freedom of expression.

The Theme of WPFD 2013 is *Safe to Speak: Securing Freedom of Expression in All Media.* This year's WPFD celebration aims to provide a forum for dialogue among media representatives, practitioners, and civil society organizations to discuss the current challenges and issues surrounding the safety of journalists in Cambodia.

Session 1 of the Day will bring perspectives from Cambodian media professionals both in print and audiovisual media. As directors, editors-in-chief, journalists, and human rights advocates working in the media sector of Cambodia, what kind challenges do they face, and what role can the government, international organizations, civil society, the media and other private sector actors play in ensuring journalists' safety? Session 2 will aim to seek solutions and bring into light the legal and regulatory frameworks in Cambodia: Are the existing legislation and regulations effective and sufficient tools to protect journalists in the country?

World Press Freedom Day 2013 will be celebrated by UNESCO Phnom Penh Office and the Office of High Commissioner for Human Rights (OHCHR) in cooperation with KonradAdenaurStiftung (KAS) Foundation, Cambodian Communication Institute (CCI), Club of Cambodian Journalists (CCJ), and the Department of Media and Communication (DMC) at the Royal University of Phnom Penh.

**For further information, please contact:**
Ms. Jamie Lee (UNESCO): 07877 21 44 or hj.lee@unesco.org
Ms. Zoe Latumbo (OHCHR): 012790178 or zlatumbo@ohchr.org